Khmer Story Lovers

ប្រុសលោមលោកប្រវត្តិតាមសម័យបុរាណចិន

## ប្រុសលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



មាណពសម្ងំស្តាប់ជីតានិងចៅផងតែកគ្នា ទើបយល់ថា កាលនាយសន្ទប់ ហើយមមើមមាយក្រោមឥទ្ធិពលធាតុក្តៅនិងគ្រផាក់លាយគ្នានេះ ចិនគុនបានលួចស្រាថ្នាំដ៏មានតម្លៃរបស់ជីតាគាត់ ទៅឲ្យនាយផឹកពល់យប់ទើបជាសះស្បើយឆាប់ម៉្លេះឬ? ដូច្នេះចិនគុនមានគុណលើនាយច្រើនណាស់, គោងទទួលទោសជំនួសនាងវិញ កុំទុកពេលឲ្យតាចាស់ស្តីបន្ទោសនាងទៀត ។

គិតឃើញដូច្នោះហើយនាយពោល :

–លោកតា ! ខ្ញុំជាអ្នកផឹកស្រាត្រូវលោកតាពីខ្ញុំវិញទេតើ! ហាំខ្ញុំខកខេកជូនលោកតាមើលសិន បើកមិនបាន សូមច្រគល់ខ្លួនជូនលោកតាហាត់វែងតាមត្រូវការ ។

តាចាស់សើចញញឹម :

– ប្រសើរណាស់ ! និយាយដូចកាប្រមក់ឯងត្រូវខ្លះ អីអាគុង, ម៉េចចៅមិននិយាយរឿងផ្ទាល់ខ្លួនប្រាប់ពុទ្ធះផង ?

ចិនគុនអេះអុញពោលថាខ្ទប់ :

–គាត់...គាត់មិនសួរខ្ញុំ, ខ្ញុំក៏មិនបាច់ប្រាប់គាត់ដែរលោកតា គេរបបរោគគាតមានតែមួយមុខទេ លោកតាកុំសង្ស័យ ។

តាចាស់ធ្វើមុខក្រញូវ :

អ្នកប្រែសម្រួល : អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ១១

- ហ៊ឹះ ! ហ៊ឹះ ! គោលបំណងយ៉ាងណាដែរចៅស្រី ? តាយល់អស់ហើយ, ចៅឯងស្រឡាញ់តាប្រមាត់នេះខ្លាំងណាស់, ចង់ឲ្យតែតាដណ្ដឹងធ្វើប្រពន្ធ ។ ប៉ុន្តែចៅឯងមិនហ៊ានប្រាប់ឈ្មោះព្រោះខ្លាចភ័យលោះព្រលឹង, ម៉្លោះហើយបេះតែលាក់រហូតទៅ ។ មែនទេចៅស្រី ?

សំដីតាចាស់ត្រូវចំបំណងធំរបស់វីនតុន ព្រោះនាងក្រែងរអែងណាស់ឥតហ៊ាននិយាយរឿងពិតប្រាប់ជីតាដោយហេតុថា លោកតាកាចឃោរឃៅណាស់ដើរសាបព្រោះគេកេកម្មគុនពិតពុនកល់ពេលវេលាអ្នកណាក៏ខ្លាចគាត់មិនហ៊ានមកជិតនិងមិនហ៊ានរាក់ទាក់ជាមួយគាត់ដែរ ។ ជីតានាងតែងតែចង់ឲ្យគេមកស្និទ្ធស្នាលនឹងគាត់ដែរ តែបើអ្នកនោះធ្វើឫកថោកទាបមកលុតក្រាបជាមួយគាត់ គាត់ប្រហារគេចោលភ្លាម ។

ពេលនេះវីនតុនលំបាកចិត្តណាស់ ព្រោះលោកតាមើលឃើញផ្ចិតគំនិតនាងទាំងអស់ បើហ៊ានក្បហកតទៅទៀតលោកតានឹងញ័រពុកមាត់ទៀតហើយ ។ បើនិយាយរឿងពិតប្រាប់ឈ្មោះពិតទៅ « បងណាន » ក៏យញាក់សាច់លោះព្រលឹងលែងហ៊ានមកជួបមុខនាងទៀតហើយ ។ តើត្រូវធ្វើយ៉ាងណាវិញ ?

## វគ្គទី ១១

## ថ្ងៃជាះខលាល្អ

វីនតុនក្តុកក្តួលជ្រួលច្របល់ជាខ្លាំង ព្រោះម៉្យាងខ្លាចក្រែងជីតាខឹងសម្លាប់បងណាន ម៉្យាងទៀតខ្លាចបងណានដឹងប្រវត្តិជីតាហើយរត់ចោលនាងចោល ។ បើបងណានស្លាប់ឬរត់ចោលនាងនោះជីវិតនាងនឹងប្រែជាឥតន័យហើយ ។ នាងពោលដោយសម្លេងញ័រ ៗ :

– លោកតា! ខ្ញុំ... ខ្ញុំ...

តាចាស់សើចហាស ៗ :

–ខ្លាចគេមើលងាយគ្រួសារយើងមែនទេ? ហាស ៗកញ្ចាស់ទីងយើងនេះអាយុប៉ុណ្ណេះហើយ ចៅស្រីនៅតែមិនហ៊ាននិយាយឈ្មោះជីតាប្រាប់គេទៀត វាមិនត្រឹមតែមិនត្រេកអរ ថែរជាស្អប់ខ្ពើមឈ្មោះវីតាវ៉ៈចៅវិញ ! ហាស ៗ ! គួរឲ្យចង់សើចណាស់ !

ពេលរួចគាត់យកដៃទះពោះសើចកាចកកាចស្រេង ។ វីនតុនយល់ថា គ្រោះថ្នាក់ជិតចូល

មកដល់ហើយ នាងភ្ញាក់ដឹងថា តាតាចាក់ចុកស្រាថ្នាំពុលជីវិតផ្ទាល់ ហើយនាងបានលួចយកទៅសង្គ្រោះជីវិតសង្សារអស់ ព្រមទាំងមិនហ៊ានរំពឹកឈ្មោះគាត់ទៀតផង ឥឡូវពេលនេះគាត់ស៊ើបទាំង១ប្រៀបបាល ជាទីនឆ្លងនេះប្រុះឆ្កួតហើយ ។

នាងនាំមាត់ម្រេចចិត្តពោលប្រាប់ស៊ីផានថា :

–បងផាន ជីតាខ្ញុំត្រកូលចិន !

– មែនហើយ បើនាងត្រកូលចិន គាត់ត្រូវតែសែចិនដែរ !

– គាត់ឈ្មោះមិនហួសបីមានន័យថា ... ថា ... មួយថ្ងៃមិនហួសបី !

នាងនឹកស្មានថា បន្ទាប់ពាក្យ«មួយថ្ងៃមិនហួសបី ចិនមិនហួសបី»នេះ ស៊ីផានច្បាស់ជាភ័យស្រទុំស្ទាំងមិនខាន ទើបនាងញ័រញាក់បេះដូងលោតក្ដុកក្ដាក់ ហើយសម្លឹងមើលនាយដោយក្ដីបារម្ភ ៗ តែស៊ីផានមាននឹកមុខធម្មតា ស៊ើបញឹមៗតបថា :

– យី ! ការលោកតាពីរោះណាស់ !

ចិនគុនភ្ញាក់ព្រើត បន្ទាប់មកនាងសែនសប្បាយ តែមិនទាន់អស់ចិត្ត ក៏សួរ:

– ហេតុអ្វីបងថាពីរោះ ?

– ខ្ញុំក៏ពុំយល់ហេតុផលដែរ គ្រាន់តែដឹងថាពិរោះប៉ុណ្ណោះ !

ចិនគុនស្ដាប់រួចងាកទៅរកជីតា , ឃើញគាត់ច្បូតពុកមាត់ញញឹមយ៉ាងពេញចិត្ត ហើយលូកដៃទះស្មាស៊ីផាន តែពុំមានបញ្ចេញកម្លាំងណាទេ ៗ គាត់ក្រវីក្បាលងើពោលថា :

–ជីវិតពស់នៅត្រូវតែមានកល្យាណមិត្ត! អ្នកឯទៀតគ្រាន់តែឮឈ្មោះមួយថ្ងៃមិនហួសបី ខ្លះជាកទាបពោលសរសើរដើម្បីផ្គាប់ផ្គុន ខ្លះកំសាកនឹកភ័យស្ទើរលោះព្រលឹង ខ្លះអង់អាចបន្តុលមុខដេរ... គឺមានតែកាប្រមក់ឯងនេះមួយគត់ដែលនៅស្ងៀមហើយសរសើរថាការតាពីរោះ! ល្អ! ល្អ! កាប្រមក់ តានឹងឲ្យរង្វាន់ឯងម៉្យាង ! ចាំតាគិតមើលមើល៍ តើឲ្យអ្វីទើបសមនឹងសំដីនេះ?

តាមពិតចិនមិនហួសបីជាបិសាចកំណាចបំផុតនៃពិភពគុន ៗ បើមិនពេញចិត្តនរណា, គាត់សម្លាប់អ្នកនោះពោលភ្លាម ៗ ថ្វីត្បិតតែដាក់កំរិតថាមួយថ្ងៃមិនសម្លាប់មនុស្សលើសពីបីនាក់មែន តែមួយថ្ងៃបីនាក់, ដប់ថ្ងៃសាមសិបនាក់, មួយរយថ្ងៃបីរយនាក់ . . . ពោះគាត់មិនសម្លាប់មនុស្សរៀងរាល់ថ្ងៃក៏ដោយ ក៏រាប់ចំនួនឆ្នាំមកនេះ គំនុំឈាមកើនឡើងជាលំដាប់ដែរ ៗ ដូនដែលត្រូវគាត់

សម្លាប់ គាត់ច្រើនលើសន្ធារតាំងមិនបានឃើញមុខគាត់ផង ដូចជាស៊ុនកន់ខាងនិងដូកន់ឈើនៃក្រុមក្ដិកកកជាដើម ។

ពីមុន គាត់សម្លាប់មនុស្សដោយមិនបញ្ចេញឈ្មោះទេ ទើបពុំសូវមាននរណាស្គាល់ តែប៉ុន្មានឆ្នាំនេះ គាត់ប្រែជាចំផ្សព្វផ្សាយឈ្មោះយ៉ាងពេញទំហឹងទៅវិញ ។

មនុស្សដែលឃើញគាត់ហើយនៅរស់កនមានជីវិត មានចំនួនតិចណាស់ ។ ចំណែកស៊ុផងាន មិនធ្លាប់ដឹងព្រឹត្តការណ៍ក្នុងពិភពគុនសោះឡើយ ទោះទីងមិនហួសបីមានឈ្មោះសាស្រ្តយ៉ាងណា ក៏គ្មានធ្វើឲ្យនាយអើលអ៊ីដែរ ។ តែទីងមិនហួសបីយល់ថា មាណពមានការគួរសមចំពោះខ្លួនណាស់ ពិសេសនៅពេលស្គាល់ឈ្មោះគាត់ហើយ នាយនៅតែបញ្ចេញអាកប្បកិរិយាស្និទ្ធស្នាលដដែល ។

ទីងមិនហួសបីអាយុហុកសិបប្លាយឆ្នាំ មានការពិសោធន៍គ្រប់គ្រាន់ក្នុងឆាកជីវិត ឲ្យតែមានបុគ្គលមិនស្របតាមចិត្តគំនិត ពិតជាគេចមិនផុតពីភ្នែកគាត់ឡើយ ។ ក្នុងលោកនេះ ក្រៅពីចៅស្រីគ្មានអ្នកណាម្នាក់ស្រឡាញ់រាប់អានគាត់ពិតប្រាកដទេ តែពេលនេះមាណពដែលមិនធ្លាប់ស្គាល់គ្នាសោះ បែរជាមានសមានចិត្តចំពោះគាត់ តើមិនឲ្យសប្បាយរីករាយម្ដេចកើត ? គាត់សញ្ជឹងគិតបន្តិចទើបពោលថា :

-គាមានវត្ថុពិសេសបីយ៉ាង មួយគឺស្រាថ្នាំដែលអាប្រមឹកឯងលួចផឹកអស់ទៅហើយ តែស្រានោះគ្រាន់តែឲ្យឯងខ្ចីទេ ថ្ងៃក្រោយត្រូវសងវិញ ។ ទីពីរគឺយុទ្ធសិល្បៈរបស់គា បើអាប្រមឹកឯងហាត់ចេះពិតជាមានប្រយោជន៍ណាស់ ។ ចំណែកវត្ថុទីបីគឺអាគុងចៅស្រីគានេះឯង ! ក្នុងវត្ថុពីរយ៉ាងខាងក្រោយនេះឯងអាចរើសយកបានតែមួយយ៉ាងគត់ ។ នែ ! អាក្មេងកំពូជ ឯងចង់ហាត់រៀនយុទ្ធសិល្បៈរបស់គាឬចង់បានអាគុង ?

សំនួរនេះធ្វើឲ្យស៊ុផងានទីងគុងស្រឡាំងកាំងមួយរំពេច ។ ពិសេសគឺទីងគុងដែលភ័យភ្លូកភ្លាក់ខឹងថា „លោកតាមានកម្រិតយុទ្ធសិល្បៈខ្ពស់លើសលុប ឯបងងានពិតមែនតែនៅខ្សោយជាងគាត់មួយកំរិតប៉ុន្តែបើបានលោកតាជួយបង្ហាត់បង្ហាញបន្ថែមទៀត ច្បាស់ជាអាចល្បីរន្ធឺពេញពិភពគុនមិនខាន ! ពត់ជានាយក្រុមឈានល្ង ហើយពួកក្រុមនេះកំពុងជួបប្រទះឧបសគ្គធំណាស់ ប្រសិនបើគាត់ហាត់យុទ្ធសិល្បៈលោកតាចេះអស់ នោះសត្រូវទាំងឡាយនឹងបាក់បែកខ្ចាត់ខ្ចាយយ៉ាងប្រាកដ ! គាត់ជាកូនប្រុសដើមទ្រូងប្រាំហត្ថពិតជាគិតកិច្ចការនាគតច្រើនជាងរឿងគូស្រករហើយ" ។

នាងគិតបណ្ដើរនាំគល្លូចមើលស៊ីផធានបណ្ដើរ ឃើញនាយធានចិត្តមុខរវើរវាយ ហាក់ដូចមិនទាន់សម្រេចចិត្ត ។ ចិន្តនុជកាន់តែបារម្ភក្តុកក្តួលជាលំដាប់ ហើយគិតទៀតថា «បងធានធ្លាប់តែមានប្រវត្តិស្នេហាល្បីល្បាញស្ទាញស្ទុះ គាត់មានសង្សារពាប់មិនអស់ ក្នុងឆ្នាំនេះគាត់ហាក់ស្ងប់ស្ងាត់នឹងយើងមែន តែក្នុងចិត្តប្រហែលជាគាត់ទុកចិន្តនុជយើងជាដុំពកដែលសោកបាត់ស្រមោលនោះហើយ ។ ម៉្យាងទៀតលោកតាមានឈ្មោះតាក្រក់ណាស់នៅក្នុងពិភពគុន ឯក្រុមឈានល្អនិងឈ្មោះស៊ីផធានពុំសូវថ្លៃថ្នូរមែន តែយ៉ាងម៉េចក៏គួរសមជាងលោកតាដែលប្រព្រឹត្តតែអំពើព្រៃផ្សៃដែរ ! បើគេដឹងប្រវត្តិយើងហើយ តើគេម៉េចនឹងស្រឡាញ់យើងទៀត ? »

នាងហានការ[illegible]ព្រឺរក្រោយខ្លួនម្ដងៗ ចិត្តក្នុងស្រលើងរណ្ដាលគួរឲ្យអាសូរ ។ ចិន្តមិនហួសបីតឿនថា:

– ចាប់និយាយមក ! [illegible] លេងកលល្បិចជាមួយតាឲ្យសោះ ! គិតណាហាក់យុទ្ធសិល្ប៍នេះ ហើយបងយកតាគុនទៀតមិន[illegible] ! តាប្រាប់ឯងឲ្យដឹងមុនថាក្នុងលោកនេះគ្មានអ្នកណាម្នាក់អាចប្រើកលល្បិចជាមួយចិន្តមិនហួសបី[illegible]ទេណា, បើចង់បានម៉្យាងត្រូវតតាំងម៉្យាង បើពុំនោះសោត ជីវិតឯងច្បាស់ជាមិនគង់វង្សទេ ! ឮឬ[illegible] ?

ស៊ីផធានតបថា:

–លោកតា ! ចិន្តចិន្តនុជនុជ, ខ្ញុំសុំផ្ដាំប្រាប់ថាច្រឡំមនុស្សហើយ ព្រោះខ្ញុំមិនមែនស៊ីផធានទេ !

ចិន្តមិនហួសបីស្ដារ :

–បើឯងមិនមែនស៊ីផធានទេ ឯងជាអ្នកណាទៅវិញ?

–ខ្ញុំមិនមែននាយក្រុម មិនមែនបងធាននៃចិន្តៗនុជៗទេ! ខ្ញុំគឺខ្មែរឥតពូជ!ខ្មែរឥតពូជគឺខ្មែរឥតពូជ ហើយគ្មានឈ្មោះណាផ្សេងទៀតទេ!

ចិន្តមិនហួសបីតបទៅវិញ :

–ល្អណាស់! តាឲ្យតែពាក្យរបស់ឯងមួយ មិនមែនមកពីឯងជានាយក្រុមឈានល្អ ឬនាយក្រុមស៊ីទេ ហើយក៏មិនមែនមកពីចិន្តនុជចូលចិត្តស្រឡាញ់ឬមិនស្រឡាញ់នោះដែរ គឺចិន្តមិនហួសបីពេញចិត្តនឹងឯង ទោះឯងជាខ្មែរឥតពូជក៏ដោយ, ជាអាបាតផ្សារក៏ដោយ ឲ្យតែចិន្តមិនហួសបីពេញចិត្តហើយ ឯងត្រូវតែទទួល មិនអាចប្រកែកបានឡើយ !

ស៊ីផានបែរមើលទីងមិនហួសប៊ី និងទីងតុង ដោយនឹកក្នុងចិត្ត ៖

- ទីងតុងយល់ច្រឡំថាយើងជាបងធានរបស់នាង ហើយបងធានពិតប្រាកដនោះ គង់មានថ្ងៃ

ណាមួយត្រឡប់មករកនាងវិញពុំខាន បើយើងស្រឡាញ់នាង ដូចជាធ្វើបាបនាងនិងបងធាននាងដែ

តែបើយើងថាមិនត្រូវការនាង នាងច្បាស់ជាឈឺចិត្តស្លាប់ហើយ ! ណ្ហើយចុះយើងមិនត្រូវការទាំងអ

ប្រហែលជាប្រសើរជាង ! ម៉្លោះហើយនាយគ្រវីក្បាលតប ៖

-លោកតា ! ខ្ញុំបានផឹកស្រាថ្នាំរបស់លោកតា ប្រហែលជាមិនងាយនឹងរកសងវិញទេ ហេតុនេ

ខ្ញុំយល់ថា ស្រានេះអាចចាត់ទុកជារង្វាន់ដែលលោកតាឲ្យខ្ញុំទៅចុះ !

ទីងមិនហួសប៊ី ថ្ងោះទឹកមុខ ៖

- មិនបានទេ ! មិនបានទេ ! ស្រានោះឯងប្រាប់ថាសងវិញ ! ឥឡូវចង់ប្រកែកឬ? មិនកើ

ទេ ! ឯងរើសរួចហើយ ឬនៅចង់បានអាតុង ឬវិជ្ជាគុន ?

ស៊ីផានលួចមើលទីងតុង តែគាប់ជួននាងកំពុងលួចមើលនាយដែរ ទើបភ្នែកប៉ះគ្នាភ្លាមម្នាក់

ប្រញាប់ងាកមុខចេញជាបន្ទាន់ ៗ ទីងតុងមានទឹកមុខស្ងួតស្ងាំងស្រក់ទឹកភ្នែករហាម បើតា

ចិត្តនាង ច្បាស់ជាចាប់មួលត្រចៀកស៊ីផាន ឬទន្ត្រាំជើងរត់ចោលនាយហើយ តែពេលនេះនៅចំពោ

មុខលោកតា នាងមិនហ៊ានបញ្ចេញឫកម៉ិកម៉ក់ទេ ៗ ឃើញទីងតុងស្រក់ទឹកភ្នែក នាយនឹ

អាណិតណាស់ ពោលលួងលោមថា ៖

-ទីងទីងតុងតុងខ្ញុំប្រាប់ហើយថានាងច្រឡំមនុស្ស បើខ្ញុំពិតជា « បងធាន » របស់នាងមែនខ្ញុំ

មិនបាច់រើសទេ ខ្ញុំច្បាស់ជាយក ... យកនាង មិនយកវិជ្ជាគុនទេ !

ទីងតុងសួរទាំងទឹកភ្នែក ៖

- បងមិនមែនបងធាន ? អ៊ីចឹងក្នុងលោកនេះមានបងធានពីរឬ ?

-ប្រហែលខ្ញុំមានមុខមាត់ប្រហាក់ប្រហែលនឹងបងធាននោះណា ?

ទីងតុងសើចទៀត ៖

- បងនៅតែ «មាត់រឹង» ទៀត ! ក្នុងលោកយើងនេះគ្មានមនុស្សដូចគ្នាបេះបិទទេ បងនឹក

មើល កាលយើងជួបគ្នាដំបូង បងលូកដៃមកចាប់ខ្ញុំ ខ្ញុំមិនស្គាល់បងបានជាយារដៃទះបង មែនទេ?

ស៊ីផានធ្វើមឹងម៉ាំងឥតនឹកឃើញរឿងដូច្នេះសោះ ៗ ទីងតុងបន្តដោយស្រងូតត្រអាក់ ៖

– អូ ! មកពីបងឈឺធ្ងន់ពេក ភ្លេចអស់ហើយឬ ? ឬបងធ្វើពើ ?

ស៊ីផានអេះក្បាលញាប់ស្អេក:

– ខ្ញុំមិនយល់សោះទេ បើខ្ញុំមិនមែន «បងផាន» នាងឲ្យខ្ញុំដឹងរឿងនាងជួបនាយក្រុមស៊ីលើកដំបូងម៉េចកើត ?

– ហ៊ឺះ ! បងចង់ប្រកែកឬ ? កាលនោះបងចាប់ដៃខ្ញុំទាំងពីរជាប់ , ខ្ញុំភ័យណាស់ ខ្ញុំរើបំរះអស់ទំហឹង , បងសើចហាស ៗ រួចហោតមក ... មក ... មករក . . ថើបខ្ញុំ ... ខ្ញុំទនមុខចុះផ្អៀងមកម្ខាង ខាំស្មាបងក្រិប ១ ចេញឈាមរហាម ទើបបងលែងដៃ ។ ឥឡូវបងដោះអាវបង្ហាញខ្ញុំសិន តើមានស្នាមធ្មេញខ្ញុំឬទេ ? កាលនោះខ្ញុំខាំជ្រៅណាស់ ទោះបងពូកែយ៉ាងណាក៏លុបមិនបាត់ដែរ ។

មាណពស្ដាប់ចប់ងក់ក្បាលដូចត្រូវជ្រួងបន្តិច:

– ត្រូវហើយ ! បើខ្ញុំឥតស្គាល់នាង , នាងខាំស្មាខ្ញុំឥតបានទេ ។ យី ! . . . ម៉េច. ម៉េចក៏មាន . . .

ពោលផងនាយដោះអាវផងស្រាប់តែញ័រខ្លួនទទ្រើកស្រែកក្ដាត់មាត់:

– ម៉េចក៏ចំឡែកម្ល៉េះ ព្រះម្ចាស់ថ្លៃអើយ !

ភ្នែកទាំងបីគូដោតផ្ចិតលើសាច់ស្មាអ្នកកម្លោះ ។ នុះនឹ ! លើស្មាឆ្វេងមានស្នាមធ្មេញរាងមូលប៉ុនវង្វះមាត់ រកប្រកែកមិនបានជាដាច់ខាត ។ ទីងមិនហួបធ្វើហ៊ុះ ពោលថា:

– អាប្រមក់ចង់ប្រកែកផង ! ទីបំផុតឃើញភស្តុតាងជាក់ស្ដែងមែន, ប្រកែកម៉េចទៀតហា: ! គាប្រាប់ឲ្យហើយណា ! ឡើងភ្នំយូរៗគង់ជួបសត្វសាហាវ យ៉ាងណាមិញឯងដើរធ្វើបាប ស្រីៗយូរគង់មានថ្ងៃត្រូវស្ត្រីណាចាប់ជាប់រើមិនរួចអីចឹង រឿងក៏វិលបែបនេះគាធ្លាប់«វៃហាល»ពីក្មេងដែរ កុំប្រាច់ឆ្ងល់ណ្ហ៊ីយ ! ឯងចង់បានអាគុនមែនទេ ?

ស៊ីផានឬមាណពចម្លែកកំពុងធ្វើភ្នែកស្ញឹងនឹកមិនឃើញថានាយត្រូវគេខាំស្មាពីកាលណា ? បើស្នាមរបួសច្បាស់ក្រឡែបែបនេះ ម្ដេចនាយភ្លេចហួសម៉្លេះ ? ប៉ុន្មានថ្ងៃនេះកើតប្រទះតែព្រឹត្តការណ៍ចំឡែកតាយមិនបានស្មានមិនត្រូវសោះ ។ ថ្ងៃមុននាយសំគាល់លេសថាប្រឡំមនុស្ស ឥឡូវភស្ដុតាងជាក់ស្ដែងយ៉ាងហ្នឹង, បានពាក្យអ្វីប្រកែកនឹងគេហ្ន៎ !

មាណពឈរធ្មឹងធ្វើភ្នែកស្ញឹស្ញាប់អ៊ីមិនព្រិច ។ ចិនម៉ិនហ្វូសប៊ីស្មានថានាយនៅក្មេង មានការអៀនខ្មាសមិនហ៊ាននិយាយគ្រប់ ទើបស្រែចហាស ១:

- អាគុន, ដោលទូកទៅផ្ទះយើងវិញ ។

ចិនគុនភ័យអរលាយឡំគ្នា សួរ:

- លោកតា ... លោកតាគតនាំគាត់ទៅផ្ទះយើងឬ ?

- យ៉ាអើ! បើវាត្រូវជាចោរប្រសាតាហើយ, ទៅឯងលែងរកឲ្យគេបាត់ទៅឬ ? បើគេបន្ទូនបាត់មែន « ចិនម៉ិនហ្វូសប៊ី » មិនអាចរស់តទៀតបានទេ ។

ចិនគុនរីកមុខដូចបុប្ផាត្រូវសន្សើម , នាងមើលមាណពម្នាក់ទៀត ក៏មានមុខក្រហមទុំដោយការអៀនខ្មាស ។ បន្ទាប់មកនាងចាប់ប្រវាស់ដោលទូកចូលក្រោមស្ពានថ្មចេញដំណើរ ។

មាណពចង់សួរគេ តើនាំខ្ញុំទៅផ្ទះណា ? តែខាយស្ដ័យរឿងច្រើនពេកក៏នៅស្ងៀមវិញ ។ ទឹកបឹងថ្លាភ្លន់ឆ្លុះឃើញស្រមោលព្រះច័ន្ទរ ១ , មាណពគ្រវែងភ្នែកមើលទេសភាពស្រមៃទៅឆ្ងាយ... ស្មឹកស្រល់ភ្ញាក់សំយុងជិតជះក្បាលនាងចិនគុន ។ ពុំគេម្ដេចរលកតិច ១ និងប្ញស្សីប៉ះគែមទូកម្ដង ១ តាមចង្វាក់អ្នកលោល... មាណពភើរភយឃុំរះវា ហាក់ភ្ញាក់ខ្លួនគុនភាពមួយថ្មីទៀតហើយ , ដូចជាយល់សប្ដិទិច មិនទែនបន្តិច ត្រូវនឹងក្លិនក្រអូបរំភាយតាមខ្យល់ដល់នាសាថែមទៀត ឆាយលែងមានអារម្មណ៍មូលផ្តុំតែម្ដង ។

. កូនទូកល្បឿនលយកាត់ផ្ទៃបឹងអស់រយៈពេលដ៏យូរ ទើបឈប់ស្ងៀម ។ មាណពឃើញចិនគុនស្រាវខ្សែទូកបោះលើកាំជណ្ដើរថ្មរំពឹងនឹងបង្គោលមួយ ហើយនាគស្រែចអាក់មាយបន្តិចទើបលោតយ៉ាងស្រាលឡើងជណ្ដើរនោះ ។ ចិនម៉ិនហ្វូសប៊ីស្រែច:

- ថ្ងៃនេះ ឯងជាភ្ញៀវកិត្តិយសរបស់យើងណា! សូមអញ្ជើញឡើងគោក !

ស៊ុផណានគ្មានពាក្យឆ្លើយតប ក៏ដើរតាមជីតានិងចៅទាំងពីរពេយ ។

- គេទៅដល់របងហើយដើរកាត់សួនច្បារមួយធំ ទើបឃើញតួបមួយនៅកណ្ដាល ។ ចិនម៉ិនហ្វូសប៊ីចូលក្នុងតួបមុន ស្រែចហាស ១ :

- អញ្ជើញចូលមក !

ស៊ុផណានដើរចូលផ្ទុកអង្គុយភ្លាម. ចិនម៉ិនហ្វូសប៊ីក្រោកក្រេងដឹកដៃចិនគុនដើរកាត់សួនច្បារទៅ

ណាបាត់ ។

ពេលនេះរាត្រីជ្រៀនជ្រេ ដួងចន្ទ្រាហាលរស្មីលើផែនពសុធា បង្ហាញឲ្យមាណពមើលអ្វី ៗ ឃើញស្រដៀងពេលថ្ងៃ ។ នាយកំពុងអផ្សុកស្មាធ្វេងស្រវៃទៅឆ្ងាយ ស្រាប់តែឮសំរឹបជើងពីចម្ងាយ គឺស្ត្រីពីរនាក់ដើរតម្រង់មកដល់, លំអោនកាយពោលថា:

- សូមអញ្ជើញកូនកម្លោះចូលទៅផ្លាស់សំលៀកបំពាក់ខាងក្នុង ។

ស៊ីផាខមិនដឹងគេចង់ធ្វើអីទេ, គ្រាន់តែយល់ថា គេហៅនាយចូលទៅក្នុង, ម្លោះហើយ-នាយក្រោកឈរដើរតាមស្រីទាំងពីរក្រោម ។ គេដើរផុតសួនច្បារដល់ផ្ទះមួយតូចច្រឡឹងដែលមានទឹកក្តៅមួយធានធំនិងកន្សែងពីរ ។ ស្រីម្នាក់សើចដាក់នាយពោល:

- សូមកូនកម្លោះងូតទឹកជំរះកាយសិន, លោកតាមានប្រសាសន៍ថា ពេលវេលាបន្ទាន់ពេកឥតបានរកខោអាវថ្មីទេ, សុំកូនកម្លោះ ពាក់ខោអាវចាស់សិនចុះ ។

ពោលហើយស្ត្រី ទាំងពីរសើចខឹកៗ នាំគ្នារត់ចេញអស់បិទទ្វារជិត ។

មាណពនៅម្នាក់ឯងម៉ងម៉ង់ នឹកថា:

-យើងឈ្មោះថ្កែតពុជសោះ ឥឡូវក្លាយជាតាំក្រុមស៊ី, ជា "បងធាន", ជាភ្ញៀវហើយ ដល់កូនកម្លោះទៀត ! យើចម្ចុកអស្ចារ្យណាស់ ។

មាណពគិតចុះឡើងមិនឃើញទងមិនហួសបី និងទីងតុងមានបំណងអាក្រក់លើខ្លួន ក៏ដោះខោអាវងូតទឹកក្តៅជំរះកាយស្អាតមានកម្លាំងព្រឹស ។ គ្រាន់តែស្លៀកពាក់ឡើងវិញរួចក្លាមឮបុរសម្នាក់ស្រែកហៅពីក្រៅ :

- សូមអញ្ជើញកូនកម្លោះទៅសំពះជូនតា ។

មាណពភ្ញាក់ព្រើតនឹកឃើញពាក្យដែលម្តាយធ្លាប់និយាយប្រាប់ពីរឿងកូនកម្លោះកូនក្រមុំសំពះជូនតានៅពេលរៀបការជាប្តីប្រពន្ធ ។ នាយស្រឡាំងកាំងនិយាយលែងចេញកំឈរធ្មឹង ។ សម្លេងស្រែកសួរទៀត:

-កូនកម្លោះស្លៀកពាក់ហើយឬនៅ ?

មាណពភ្ញាក់ព្រើតឆ្លើយ: រួចហើយៗ !

បុរសនៅខាងក្រៅប្រានទ្វារដើរចូលមក លើកកន្សែងក្រហមបង់កឲ្យនាយ ហើយដោតផ្កាកុលាប

មួយខនលើកការផេន ។ បន្ទាប់ពីនោះគេសើចស្រស់ ពោលពាក្យគួរសម:

- សួស្តីកូនកម្លោះ!

គេដឹកដៃមាណពដើរចេញទៅ ។ ស៊ីផាននឹកភ័យស្រយ៉ាំងកាំង ដើរតាមគេដូចយល់សប្តិ ដល់បន្ទប់មួយធំភ្លឺចិញ្ចាច ។ នាយឃើញគេដោតទៀនធំៗ ប្រាំបីដើមព្រោងព្រាតលើតុ ដែលក្រាលកំណាត់ក្រហម ។ ទីនមិនហួសបីឈរកណ្ដាលបន្ទប់ញញឹមជាប់ ។ លុះស៊ីផានចូលដល់ បុរសបីរូបនាំគ្នាផ្លុំភ្លេងលាន់ទ្រហឹង ម្នាក់វាយឃ្មោះម៉ាងៗ, ពីរនាក់ដើរមកទទួលមាណពចូលក្នុងដោយពោលខ្លាំងៗ:

- សូមកូនក្រមុំចេញមក!

គេឮសម្លេងគងៈដីងប៉ះគ្នារ៉ឺងៗ តាមដំណើរនារី ហើយឃើញស្ត្រីចំណាស់ពីររូបអមកូនក្រមុំបាំងមុខនឹងកំណាត់ក្រហមជិត ។ នាងពាក់អាវពណ៌ស្វាយមានបុកពាទិនឹកវងរៅជាទីនគុងពិតប្រាកដ ។ ស្ត្រីចំណាស់ដឹកដៃកូនក្រមុំមកឈរខាងស្តាំមាណព ។ ក្រោមពន្លឺទៀន ទីនភ្លឺនឹមចន្ទ៍ មាណពរឹតតែរវើរវាយលើសដើម ដូចទីនមោង ។

ខណៈនោះបុរសម្នាក់ស្រែកថា សំពះមេឃ!

មាណពបែរមើលទីនគុងឃើញនាងងាកទៅលំអោនកាយសំពះមាត់ទ្វារ ។ នាយញ្រាកមិនទាន់ដឹងធ្វើយ៉ាងណា , បុរសឈរក្បែរនោះខ្សឹបប្រាប់ថា :

- លុតជង្គង់សំពះភ្លាមទៅ!

ពោលផងច្រានខ្នងនាយផង ។ មាណពនឹកថា មិនសំពះមិនកើតទេ!

ស៊ីផានលុតជង្គង់សំពះផ្ដេសផ្ដាស ធ្វើឲ្យស្រីចំណាស់ដែលកាន់ដៃទីនគុងធ្លាយសំណើចខឹក ។ បុរសនៅក្បែរកូនកម្លោះ ស្រែកទៀត :

- សំពះដី!

ស៊ីផាននិងទីនគុង ងាកមុខមកសំពះដី ។ រួចហើយបុរសដដែលស្រែកប្រាប់:

- សំពះជូនគា!

ទីនគុងលុតជង្គង់សំពះ ទីនមិនហួសបីភ្លាម ។ មាណពញ្រាកមួយសន្ទុះទើបក្រាបសំពះតាមក្រោយ ។ បុរសស្រែកបញ្ចាប់:

- ប្ដីប្រពន្ធសំពះគ្នាហ្នឹង !

ស៊ីផានឃើញចិនគុនលុតជង្គង់សំពះនាយផ្ដើតៗ នាយស្រែកខ្លាំងៗ :

- លោកតា ! ចិនៗគុនៗ ! ខ្ញុំមិនមែននាយក្រុមស៊ីហើយមិនមែនឋង់ផានទេ ៗ បើប្រព្រឹត្តបែបនេះថ្ងៃក្រោយ . . ថ្ងៃក្រោយកុំបន្ទោសខ្ញុំណា !

ចិនមិនក្លួសប៉ះសើចហាសៗ :

- យី ! តាប្រុមកនេះល្ងើយមែន ! និយាយដូចកូនក្មេងរៀនធ្វើចិន ! គេមិនប្រកាន់មិនបន្ទោសឯងទេ !

ស៊ីផានពោលថា :

- ចិនៗ គុនៗ និយាយគ្នាឲ្យច្បាស់លាស់សិនមើល ! យើងសំពះមេឃសំពះដីលេងៗ ឬមែនទែនហ្នឹង ?

ចិនគុនសំពះគួនកម្ទោះ ហើយឮតាបែបនេះនាងប្រាំមិនបានសើចទឹកភ្នែកពីក្នុងកំណាត់ ក្រហាមបាំងមុខ ហើយពោល:

- ការធំបែបនេះគេមិនដែលធ្វើលេងទេ ឋង់ផាន,យើងសំពះមែនទែនណា !

- ថ្ងៃនេះខ្ញុំប្រាប់ហើយ នៅតែមិនស្ដាប់,ប្រយ័ត្នថ្ងៃក្រោយនាងស្ដាយ, នាងចិន កុំមួលស៊ីកត្រចៀកឬខាំស្មាខ្ញុំទៀត មិនបានទេណា !

អ្នកនៅក្នុងបន្ទប់ទាំងប៉ុន្មានសើចគិល,ចិនគុនទ្រាំមិនបានពោលតបៈ

-ខ្ញុំមិនស្ដាយទេ! ឲ្យតែបងស្រឡាញ់ថ្នាក់ថ្នមខ្ញុំ .. ខ្ញុំមិនមួលស៊ីកត្រចៀកឬខាំស្មាបងទៀតឡើយ

ចិនមិនហួសចិត្តគ្រាន់ណាស់ស្រែកតកម:

-ប្ដីប្រពន្ធមួលស៊ីកត្រចៀកជាការធម្មតា មានតាំងពីព្រេងនាយមកម៉្លេះ ៗ អាឡក់តពូជ.ចិនគុនសំពះឯងយូរហើយ ម៉េចឯងមិនទាន់សំពះតបវិញ?

មាណពតាល់ប្រកន្ទ័យបាទៗ ... រួចលុតជង្គង់សំពះចិនគុនភ្លាម ៗ រួចក៏ក្នុងនេះហើយបុរសឈរក្បែរនោះស្រែកឲ្យពរ:

- ប្ដីប្រពន្ធសំពះគ្នារួច ត្រូវចូលក្នុងបន្ទប់ថ្មី ៗ សូមឲ្យស្វាមីភរិយាជួបប្រទះតែនឹងសុភមង្គលជានិច្ចលុះត្រាអវសានជាតិណា !

ខណៈនោះសម្លេងខ្លុយនិងឃ្មោះលាន់រំពង ៗ ស្ត្រីម្នាក់កាន់ទៀនក្រហមមួយគូនាំផ្លូវ, ស្ត្រីចាស់ម្នាក់កាន់ដៃចិនគុង, បុរសដែលនាំស៊ីផានចូលក្នុងបន្ទប់ថ្មី ដែលរៀបតុបតែងដោយក្រដាសក្រហមពាសពេញព្រមទាំងកូនគោមព្រោងព្រាតគួរសប្បាយណាស់ ។ ចាស់ៗនាំចិនគុងនិងស៊ីផានទៅអង្គុយលើគ្រែ ហើយចាក់ស្រាពីរកែវដាក់លើតុ ទើបពោលព្រមគ្នា :

- សូមអ្នកប្រុសនិងអ្នកនាងជួបប្រទះសេចក្ដីសុខសេចក្ដីចំរើនតរៀងទៅកុំបីឃ្លាត ៗ

បន្ទាប់ពីនោះគេនាំគ្នាសើចក្អាកក្អាយដើរចេញអស់ ទើបបិទទ្វារបន្ទប់ ៗ

មាណពអង្គុយលើគ្រែក្បែរចិនគុងកំពុងភ័យក្ដុកក្ដាក់ណាស់ ។ នាយយល់តែម្យ៉ាងថា កាលណាគេសំពះមេឃសំពះដីនិងសំពះដូនតា គេត្រូវបានគ្នាជាប្ដីប្រពន្ធ ៗ ពេលនេះ ចាស់ទុំចេញទៅអស់, នាយមិនដឹងរកពាក្យអ្វីនិយាយជាមួយចិនគុងក៏ធ្វើក្អកក្អឹះ នឹកចុះនឹកឡើង ទីបំផុតនាយពោល:

- ចិន ៗ, គុង ៗ, បិទកំណាត់ជិតក៏ចឹង មិនថប់ដង្ហើមទេឬ?

ចិនគុងសើចស្រស់ :

- ថប់ដង្ហើមណាស់, សូមបងជួយយកចេញផង ៗ

ស៊ីផានលូកដៃបើកកំណាត់ក្រហមថ្នមៗ ពេលលើកឡើង ឃើញមុខចិនគុងស្រស់ប្រិមប្រិយដូចទេពអប្សរ ក្រោមពន្លឺទៀនភ្លឺផ្លេ ៗ ៗ នាយភ័យផងអរផង សម្លឹងនាងក្រមុំមិនដាក់ភ្នែក ហើយពោល :

- នាង ... នាងល្អមើលណាស់ ៗ

ចិនគុងញញឹមសង្កៀមចេញខួចពីរ រឹតតែស្រស់ឡើង រួចឱនមុខចុះ ៗ ពេលនេះស្រាប់តែ ឮ សម្លេងចិនមិនហួសបីបន្ទប់ខាងក្រៅបន្ទប់ថា :

- យប់នេះជាពេលសុភមង្គលរបស់ចៅស៊ីយើង មិត្តមកពីខាងណា? សូមអញ្ជើញផឹកស្រាលេងសិន +

សម្លេងមួយតប :

- ខ្ញុំបាទនាមពៅហាស៊ី ជាសេនាលោកនាយក្រុមត្រកូលសុខាងក្រុមឈានល្អ, សុំជំរាបសួរលោកចិនមិនហួសបី ទាំងកក្រើបែបនេះដូចជាមិនសមទេ, សូមមេត្តាអភ័យទោសផង ៗ

ស៊ីផានពោលតិចៗក្នុងបន្ទប់ប្រាប់ចិនគុង ៖

– លោកគ្រូពេទ្យមករកខ្ញុំហើយ ។

ចិនគុងជ្រួញចិញ្ចើមលើកម្រាមដៃដាក់លើមាត់ជាសញ្ញាហាមមិនឲ្យនាយនិយាយតៗ ។ នៅខាងក្រៅចិនមិនហួសប៊ីសើចហាសៗ ៖

– ខ្ញុំស្មានតែនរណាមកលួចមាន់លួចទា មិនដឹងអស់មិត្តខាងក្រុមឈានល្អមកសោះ ។ ឥឡូវផឹកស្រាឬមិនផឹក ? សុំកុំឡូឡានៅទីនេះ នាំខានចៅប្រុសចៅស្រីយើង ។

សំដីនេះព្រហើនហួសហេតុ តែពៃហស៊ីមានការពិសោធន៍ច្រើន ហើយជាចាស់ទុំ ចេះអត់ធ្មត់ណាស់, គាត់មិនខឹងទេ បែរជាក្អកខេះៗពោលដោយក្អាក់ ៖

– អូ ! ថ្ងៃនេះចៅស្រីលោកចិនមិនហួសប៊ីរៀបការផងឬ ? ពួកខ្ញុំមិនដឹងទាល់តែសោះ ទើបឥតយកជំនូនមកចងដៃ ។ ណ្ហើយ ! ចាំថ្ងៃក្រោយសឹមមករំខានលោកតាស្រាផឹក ! យប់នេះយើងមានការសំខាន់ចង់សុំជួបលោកនាយក្រុមស៊ីសួរយោបល់បន្តិច, សូមលោកចិនមេត្តានាំគាត់ចេញមកមួយភ្លែត ។ បើគ្មានការចាំបាច់ យើងមិនហ៊ានមកកន្លែងលោកទេ ទោះក្លាហានយ៉ាងណាក៏ដោយ ។

ចិនមិនហួសប៊ីតប ៖

– លោកគ្រូពេទ្យ ! លោកជាអ្នកក្លាហានចាស់ទុំនៃពិភពគុនដែរ មិនបាច់គួរសមនឹងយើងដល់ថ្នាក់នេះទេ ។ នាយក្រុមស៊ីរបស់លោកជាឆ្កែឥតពូជ ទៅប្រសាយើងនោះឬ ? គេប្រាប់យើងថ្មីៗនេះថា ពួកលោកច្រឡំមេកោយហើយ, មិនបាច់ជួបវាទេលោក ។

អ្នកក្លាហានប្រាំបីរូបខាងក្រុមឈានល្អ ដែលបានមកជាមួយពៃហស៊ី ឮចិនមិនហួសប៊ីប្រមាថនាយក្រុមស៊ីជាឆ្កែឥតពូជ គេធ្វើហ៊ឹះៗតាមចង្រមុះ បញ្ចេញអាកប្បកិរិយាខឹងប្រឡោតក្រាម ។

ពៃហស៊ីធ្លាប់ឮនាយក្រុមថាគាត់ជាឆ្កែឥតពូជដែរ ទើបយល់ថាចិនមិនហួសប៊ីមិនមែនប្រមាថនាយស៊ីទេ ។ គ្រូពេទ្យដឹងទៀតថាលោកនាយក្រុមចូលចិត្ត «លេងសើច» តាំងពីដើមមក, យប់នេះគាត់មកសំណាក់ផ្ទះដែលមានចៅក្រមុំ មិនជាការប្លែកឡើយ ។ ប៉ុន្តែគាត់ស្មានមិនដល់ថានាយក្រុមបានធ្វើចៅប្រសាចិនមិនហួសប៊ីយ៉ាងឆាប់រហ័សដូច្នេះសោះ ។ លោកគ្រូបារម្ភខ្លាចក្រែងថ្ងៃក្រោយ

លោកនាយក្រុមមានគ្រោះថ្នាក់,ក្រុមឈានលួចផ្ញួសត្រូវថែមទៀត ពិបាកធ្វើការណាស់ ម្ល៉ោះហើយ
គាត់បញ្ជាក់:

- លោកទ័ងមិនហួសពី ! យើងខ្ញុំមានការបន្ទាន់ណាស់ត្រូវសុំសេចក្ដីសម្រេចពីលោកនាយក្រុមជាដាច់ខាត ! បើលោកនាយក្រុមចូលចិត្តមកលេងជាមួយចៅប្រើលោក ជាការធម្មតាទេ, យើងខ្ញុំឥតហ៊ានរំខានឡើយ ។

ស៊ីផានស្ដាប់តៅហៃស៊ីនឹកថា:

- កាលយើងឈឺអន្ទះអន្ទែងឥតដឹងខ្លួនប្រាណ មានតែលោកគ្រូតៃនេះហើយ ដែលជួយមើលថែរក្សាព្យាបាលដោយស្មោះស្ម័គ្រ ។ ពេលនេះមិនត្រូវឲ្យគាត់ព្រួយបារម្ភគិតគូរឿងសំខាន់ម្នាក់គាត់ទេ ។

គិតហើយនាយដើរទៅរកបង្អួច ប្រាន់បើករូបស្រែកខ្លាំងៗ:

- លោកគ្រូតៃអើយខ្ញុំនៅទីនេះទេ ! មានការអីទៅ ?

តៅហៃស៊ីឆ្លើយដោយរីករាយ :

- បាទៗ , យើងខ្ញុំមានការសំខាន់ ហើយបន្ទាន់ណាស់ ចង់ជំរាបលោកនាយក្រុមភ្លាម ៗ

ស៊ីផានតប :

- ខ្ញុំជាខ្ញុំឥតពូជមិនមែននាយក្រុមអស់លោកទេ ៗ បើចង់រកខ្ញុំទើបឃើញ, ចង់រកនាយក្រុមមិនងាយឃើញទេ ៗ .

តៅហៃស៊ីអៀនក្រហមគុម្ពត្រចៀក :

- លោកនាយក្រុមបានប្រកាសថា កំប្លែងទៀតហើយ ! សុំអញ្ជើញចេញមក, ខ្ញុំជំរាបរឿងមួយ !

មាណពសួរដោយល្ងង់ថា :

- ឲ្យខ្ញុំចេញទៅក្រៅឬ ?

- បាទ ! អញ្ជើញមកឆាប់ឡើង ។

ទីនគុនដើរតាមមាណព ទាញដៃការជាប់ពោលថា :

- បងបានកុំចេញទៅអី !

- ទេ ! ខ្ញុំទៅប្រាប់គាត់ឲ្យច្បាស់លាស់បន្តិច រួចត្រឡប់មកវិញភ្លាម ។

ពេលចប់នាយលោកផ្ទោតចេញតាមចន្លោះទៅ ឃើញតៃហស៊ុយឈរលើរបង ដាច់ "
ក្រោយខ្នងគាត់សុទ្ធតែសហការីក្នុងក្រុមឈានល្បុកតាំងប្រាំបីរូប ។ ទីងមិនហួសបីអង្គុយលើប្រគាបឈើយោលជើងចុះឡើងដូចកូនក្មេង ។ កាលបើឃើញមាណពលោតចេញពីចន្លោះមក, គាត់សួរ :

- អីលោកគ្រូតៃ ! រឿងសំខាន់ដែលចង់ប្រាប់ទៅប្រុសាយើងនោះ, យើងសុំស្ដាប់ផងបានដែរ ?

តៃហស៊ុយតបដែរ :

- កញ្ញាស់នេះ គ្មានដឹងខ្យល់អីសោះហ្ន៎ ! យើងមករកលោកនាយក្រុមទាំងអធ្រាត្រ គឺច្បាស់ជាមានការសម្ងាត់ហើយសំខាន់នៅក្នុងក្រុម, ម្ដេចគាត់សុំស្ដាប់ដែរ ? មែន ! ពាក្យចាស់អា-កមកលជាលពេញពិតពុនថាកញ្ញាស់នេះគាចសាហាវយង់ឃ្នងឥតគោរពច្បាប់ទម្លាប់ មិនខុសឯណា !

គ្រូពេទ្យដែលតិតគិតឃើញដូច្នេះក៏ឆ្លើយ:

- រឿងនេះខ្ញុំមិនអាចសម្រេចបានទេ, លោកនាយក្រុមនៅទីនេះស្រាប់ហើយ, សូមលោកសួរខ្លួនឯងចុះ ។

ទីងមិនហួសបីយោលជើង តបដោយរីករាយ :

- ល្អ ! ល្អ ! ឯងទម្លាក់រឿងនេះលើខ្លួនទៅប្រុសាយើងហើយណា ! នៃត្រកូលតពូជ, លោកគ្រូពេទ្យចង់និយាយជាមួយឯងពីរឿងអី ? ឲ្យគាស្ដាប់ផងបានទេ ?

- បើលោកគាចង់ស្ដាប់ក៏ស្ដាប់ទៅ, មានទាស់ខុសអី ។

ទីងមិនហួសបីក្លាយសំណើចក្អាកក្អាយ :

- នេះបានហៅទៅប្រុសា ពេះគោរពលោកគា !

-អីលោកគ្រូតៃ! មានរឿងអីឆាប់និយាយមក ។ យប់នេះហានតម្លៃណាស់, បៅស្រីយើងនៅរង់ចាំការត្តឥតពូជក្នុងបន្ទប់ឯណោះនំ ! កញ្ញាស់ឯងមកឥុកឡុកទៅយើងឲ្យនៅទ្បាកកណ្ដាលដំណេកថែបហ្នឹង មិនស្រួលទេណា !

តៃហស៊ីឥតស្មានថានាយក្រុមឆ្លើយឆ្លាល្ហួយថែបនេះទេ ។ គាត់រកប្រកែកមិនបានក៏ពោល

យ៉ាងនឹងថា:

—មានភ្ញៀវមកពីភូមិទឹកកក សុំជួបលោកនាយក្រុម ។

ស៊ីផាងងក់ក្បាល ហើយសួរ:

—ភូមិទឹកកករបស់អ្នកនាងហ្វូវ៉ាន់ជីនោះឬ ?

ក្នុងពិភពគុនសម័យនោះមានក្រុមបក្សអ្នកគុនច័យមកប៉រយ ៗ ស៊ីផាងស្គាល់តែភូមិទឹកកក ដួយតត់ហើយក្នុងចំណោមសមាជិកក្រុមនេះនាយស្គាល់តែហ្វូវ៉ាន់ជីទេ ទើបសួររកឈ្មោះនាងតែម្តង ។

តៃហ៊ាស៊ុំតប:

—បាទ ! អ្នកនាងហ្វូក៏មានមកដែរ, ក្រៅពីនោះមានសមាជិកជាន់ខ្ពស់ប៉ុន្មាននាក់ដឹកនាំដោយអ្នកក្លាហានទិសឧត្តរត្រកូលប៉ាយ ...

ពោលដល់គេះតៃហ៊ាស៊ុំឈប់មួយស្របក់ដើម្បីពិនិត្យទឹកមុខលោកនាយក្រុម ៗ ពន្លឺព្រះច័ន្ទបាំងចំមុខមាណពពន្លាញឡើងត្រចះពន្លឺដែលគេមើលច្បាស់ដូចថ្ងៃ ។ គាត់ឃើញនាយក្រុមធ្វើមុខស្មើ គាត់កែកយណាស់នឹកថាលោកនាយក្រុមមានអាកប្បកិរិយាថ្លៃថ្នូរបេះអត់ធ្មត់មិនឲ្យគេចាប់ផ្តាក់បានមែន !

គាត់ពោលបន្ត:

—ប៉ាយរ៉ាន់ផាងទាំងសិស្សរួមគ្រូប្រហែលប្រាំពីរ ឬ ប្រាំបីនាក់មកដែរ ៗ មើលទៅសុទ្ធជាអ្នកក្លាហាននៃភូមិទឹកកកហើយ ។

ទីងម៉ិនហ្វូសប៊ីពោលគាត់ :

— យើស ! ទោះកញ្ចាស់ប៉ាយជីតាយមកខ្លួនឯង ក៏យើងមិនញញើតដែរ ! លោកគ្រូតៃល្បីល្បាញខាងយុទ្ធសិល្ប: « ប្រាំគុណនឹងប្រាំមួយ » ណាស់ដែរ , ម្តេចគ្រាន់តែឃើញប៉ាយរ៉ាន់ជាងមក ក៏ភ័យសម្បើមម្ល៉េះ?

តៃហ៊ាស៊ុំគ្រេកអរអរនេក នឹកថា:

— កញ្ចាប់ប៉ិសាចនេះក្អេងក្អាងណាស់ , មើចមកអួតគុនវិជ្ជាយើងទៅវិញ ?

Khmer Story Lovers

(នៅមានត)

ដំកល់ទុកតាមលេខ ៣០៧ ចុះថ្ងៃទី ២២-៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់